ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :..........៣៧១..........ក.ប/ប្រ.ក

# ប្រកាស
# ស្តីពី
# ការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល អាណត្តិទី១៣

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញប្រកាសលេខ១៤១សកបយ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មការប្រឹក្សាគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា
- បានឃើញប្រកាសលេខ០៩៩សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល
- បានឃើញប្រកាសលេខ១៣០កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល
- បានឃើញលិខិតលេខ ACF០៣២/១៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ របស់នាយកប្រតិបត្តិស្តីទីមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំតែងតាំងអាជ្ញាកណ្តាលសម្រាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាល អាណត្តិទី១៣

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាអាជ្ញាកណ្តាល អាណត្តិទី១៣ ដែលមានសមាសភាពដូចខាងក្រោម៖

**I-សមាជិកដែលស្នើឡើងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ÷**

| | | |
|---|---|---|
| ១- លោក | **អាំង អេងថុង** | សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ២- ឯកឧត្តម | **សុខ ម៉ាធឿន** | ទីប្រឹក្សាក្រសួងសាធារណការ និងដឹកជញ្ជូន |
| ៣- លោក | **គង់ ផល្លៈ** | សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

| | | |
|---|---|---|
| ៤- លោក | គីម យ៉ាតដារ៉ារិទ្ធ | សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ៥- លោក | ម៉ែន ម៉ុនឈា | សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ៦- លោក | ម៉ែន និម្មិត | នាយកប្រតិបត្តិស្តីទីនៃមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល |
| ៧- លោក | ញាន សុម្មុន្និទ្ធ | ទីប្រឹក្សាច្បាប់ជាន់ខ្ពស់ នៅ HBS Law Firm |
| ៨- លោក | តាំង ទ្រី | សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ៩- លោក | រុន សារ៉ាយ | នាយកប្រតិបត្តិនៃអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា |
| ១០- លោក | កុយ នាម | សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |

**II-សមាជិកដែលស្នើឡើងដោយសមាគមនិយោជក ÷**

| | | |
|---|---|---|
| ១- លោកស្រី | ឈឹម តិរម្យ | សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ២- លោក | ហែម ហ្វណារិទ្ធ | ប្រធានការិយាល័យមេធាវី ប៊ីអេនជី (BNG Legal) |
| ៣- លោក | អ៊ឹង សុទ្ធី | សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ៤- លោកស្រី | សេង ទូចហ៊ុន | ប្រធានការិយាល័យមេធាវីនៃក្រុមមេធាវីអាស៊ីកម្ពុជា |
| ៥- ឯកឧត្តម | គល់ វឌ្ឍនា | អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា |
| ៦- លោក | លី តៃសេង | សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ៧- លោក | ម៉ារ សំបូរណា | សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ៨- លោក | អ៊ុក វី | សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ៩- ឯកឧត្តម | កៅ ថាច | អគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ |
| ១០- លោកស្រី | យូ សួនទី | សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |

**III-សមាជិកដែលស្នើឡើងដោយសហជីព កម្មករនិយោជិត (សហព័ន្ធសហជីព) ÷**

| | | |
|---|---|---|
| ១- លោកស្រី | អាន ធីរៈ | សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ២- លោក | លីវ សុវណ្ណា | សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ៣- លោក | អន ណាន | ទីប្រឹក្សារបស់សមាគមសិទ្ធិកម្មករ ដែលមានទីតាំងនៅទីក្រុង វ៉ាស៊ីនតោនឌីស៊ី (សហរដ្ឋអាមេរិក) |
| ៤- លោក | វ៉េន ពៅ | សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ៥- លោក | ហួន ជុនឌី | ប្រធានកម្មវិធីនៃមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ |
| ៦- លោក | សុង វណ្ណស៊ីន | មន្ត្រីកម្មវិធីច្បាប់នៃសហគមន៍អឺរ៉ុប (ផ្នែកអភិបាលកិច្ច) |
| ៧- លោក | សួង សុផល | សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ៨- លោកស្រី | ស៊ីន គីមស៊ាន | សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ៩- ឯកឧត្តម | ទួន ស៊ីផាន់ | សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាអនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី |
| ១០- លោក | វង្ស វណ្ណា | សាស្ត្រាចារ្យផ្នែកច្បាប់ |

**ប្រការ២.-**

យោងតាមមាត្រា៣១២ នៃច្បាប់ស្តីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាល មានភារកិច្ចដូចតទៅ ៖

១- ក្រុមប្រឹក្សាអាជ្ញាកណ្តាលគ្មានភារកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុង កំណត់ហេតុមិនព្រមសះជា ឬបញ្ហាដែលកើតក្រោយការធ្វើកំណត់ហេតុ ជាផលវិបាកផ្ទាល់នៃការវិវាទនោះតែប៉ុណ្ណោះ។

២- ក្រុមប្រឹក្សានេះ ដោះស្រាយជាផ្លូវច្បាប់ចំពោះការវិវាទដែលទាក់ទងនឹងការបកស្រាយ និងការអនុវត្តបញ្ញត្តិច្បាប់ ឬអនុសញ្ញារួមណាមួយ។ ក្រុមប្រឹក្សានេះដោះស្រាយដោយសមធម៌ ចំពោះការវិវាទឯទៀតទាំងអស់។

៣- ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអំណាចធំទូលាយ ដើម្បីស៊ើបអំពីស្ថានភាពសេដ្ឋកិច្ច នៃសហគ្រាស និងស្ថានភាពខាងសង្គមកិច្ចនៃកម្មករនិយោជិត ដែលជាសាមីខ្លួនក្នុងការវិវាទ។

៤- ក្រុមប្រឹក្សានេះមានអំណាចអង្កេតគ្រប់យ៉ាងនៅទីកន្លែងសហគ្រាស ឬអង្គការវិជ្ជាជីវៈផ្សេងៗ ព្រមទាំងអាចមានអំណាចចាត់ឱ្យភាគីជូនឯកសារ ឬព័ត៌មានខាងសេដ្ឋកិច្ច គណនេយ្យ ស្ថិតិ ហិរញ្ញវត្ថុ ឬរដ្ឋបាល ដែលមានប្រយោជន៍ក្នុងការបំពេញបេសកកម្មខ្លួន។ ក្រុមប្រឹក្សានេះ អាចសុំឱ្យអ្នកជំនាញការជួយបានទៀតផង។

៥- សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវលាក់អាថ៌កំបាំងវិជ្ជាជីវៈចំពោះព័ត៌មាន និងឯកសារទាំងឡាយ ដែលគេបានជូនមកឱ្យខ្លួនពិនិត្យ និងចំពោះហេតុការណ៍ទាំងអស់ ដែលខ្លួនបានដឹងក្នុងការបំពេញបេសកកម្មខ្លួន។

៦- ការប្រជុំនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវប្រព្រឹត្តទៅដោយបិទទ្វារ។

**ប្រការ៣.-**

កិច្ចដំណើរការ អំណាចយុត្តាធិការ ការចេញសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសលេខ០៩៩សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ព្រមទាំងវិធាននៃនីតិវិធីដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ០៩៩ នេះផង។

**ប្រការ៤.-**

សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអាណត្តិមួយឆ្នាំដោយគិតចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ ២០១៥។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល ÷**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
-គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-គ្រប់សមាគមនិយោជក
-គ្រប់សហព័ន្ធសហជីព
"ដើម្បីជូនជ្រាប"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ